**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ពុធ ៦ កើត ខែ ជេស្ឋ ឆ្នាំ រោង ឆស័ក ព.ស ២៥៦៨*
*រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីជំនួបពិភាក្សាការងាររវាង
# ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម ម៉ាសាស៊ូហ្គូ អាសាកាវ៉ា
# (Masatsugu Asakawa) ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

កាលពីរសៀលថ្ងៃពុធ ៦កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងទី ១២ ខែ មិថុនា ឆ្នាំ ២០២៤ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម **ម៉ាសាស៊ូហ្គូ អាសាកាវ៉ា** (Masatsugu Asakawa) **ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB)** ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០២៤ និងអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធស្ថានតំណាងថ្មីរបស់ ADB ប្រចាំកម្ពុជា ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម **ម៉ាសាស៊ូហ្គូ អាសាកាវ៉ា** និងសហការី ក្នុងឱកាសបំពេញទស្សនកិច្ចនៅកម្ពុជា និងសាទរជាថ្មីម្តងទៀតចំពោះការសម្ពោធស្ថានតំណាងថ្មីរបស់ ADB ប្រចាំកម្ពុជា ព្រមទាំងវាយតម្លៃខ្ពស់ចំពោះការចូលរួមចំណែកដ៏សំខាន់របស់ ADB ដែលបានផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អក្នុងការគាំទ្រកម្ពុជាក្នុងដំណើរអភិវឌ្ឍន៍សេដ្ឋកិច្ច ចាប់តាំងពីឆ្នាំ ១៩៩២ មក ។

ឯកឧត្តម **ម៉ាសាស៊ូហ្គូ អាសាកាវ៉ា** បានថ្លែងកោតសរសើរ ចំពោះការដឹកនាំប្រកបដោយសុច្ឆន្ទៈ និងការយកចិត្តទុកដាក់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក្នុងការគាំទ្រដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ជាអាទិភាពរបស់កម្ពុជា ហើយឯកឧត្តមក៏បានគូសបញ្ជាក់ឡើងវិញនូវជំហររឹងមាំរបស់ ADB ក្នុងការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រដល់ដំណើររបស់កម្ពុជាឆ្ពោះទៅរកវិបុលភាពសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព ។ **ឯកឧត្តម** ក៏បានថ្លែងអំណរគុណរាជរដ្ឋាភិបាលកម្ពុជា ដែលបានសហការយ៉ាងជិតស្និទ្ធជាមួយ ADB ក្នុងការរៀបចំ **"យុទ្ធសាស្ត្រភាពជាដៃគូសម្រាប់អភិវឌ្ឍន៍កម្ពុជា ឆ្នាំ ២០២៤-២០២៨ (CPS 2024-2028)"** ក្រោមសសរស្តម្ភចំនួន ៣ គឺ÷ **១)** ការពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច ដែលនាំមុខដោយវិស័យឯកជន, **២)** ការលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស, និង **៣)** ការពង្រឹងភាពធន់នឹងបម្រែបម្រួលអាកាសធាតុ ។

ឆ្លៀតក្នុងឱកាសនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណ ADB ដែលបាន និងកំពុងសកម្មគាំទ្រកម្ពុជាឈានសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ស្របតាម **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** តាមរយៈការរៀបចំ **"យុទ្ធសាស្ត្រភាពជាដៃគូសម្រាប់អភិវឌ្ឍន៍កម្ពុជា ឆ្នាំ ២០២៤-២០២៨"** ប្រកបដោយប្រសិទ្ធភាព និងភាពឆ្លើយតបនឹងយុទ្ធសាស្ត្រជាអាទិភាពរបស់រាជរដ្ឋាភិបាលដូចមានចែងក្នុង **"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១"** ព្រមទាំងបាន

សន្យាបន្តផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងទំហំប្រមាណ ១,២៦ ប៊ីលានដុល្លារអាម៉េរិក ក្រោមក្របខណ្ឌ **"យុទ្ធសាស្ត្រភាពជាដៃគូសម្រាប់អភិវឌ្ឍន៍កម្ពុជា ឆ្នាំ ២០២៤-២០២៨"** នេះ ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានមានប្រសាសន៍បញ្ជាក់ ក្រោមការដឹកនាំដ៏ប៉ិនប្រសព្វ, ឆ្លាតវៃ និងម៉ឺងម៉ាត់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា បានដាក់ចេញនូវ **"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១"** ដោយផ្តោតលើអាទិភាពគន្លឹះ ចំនួន ៥ គឺ **មនុស្ស, ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យាឌីជីថល** និងមានគោលដៅយុទ្ធសាស្ត្រចំនួន ៥ គឺ÷ ការសម្រេចបាននូវកំណើនសេដ្ឋកិច្ច ៧% ប្រចាំឆ្នាំ, ការបង្កើនការងារ (ទាំង បរិមាណ និងគុណភាព), ការកាត់បន្ថយភាពក្រីក្រ, ការពង្រឹងប្រសិទ្ធភាពការងារ និងចីរភាពនៃការអភិវឌ្ឍសង្គមជាតិ និងការកសាងភាពធន់ ។

ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានស្វាគមន៍ និងគាំទ្រទាំងស្រុងលើគោលដៅប្រកបដោយមហិច្ឆតារបស់ ADB ក្នុងការប្រែក្លាយខ្លួនជាដៃគូអភិវឌ្ឍន៍ពហុភាគីធំបំផុតនៅកម្ពុជា ក្នុងការផ្តល់ឥណទានដល់វិស័យឯកជនសម្រាប់ពង្រីកធុរកិច្ច និងប្រតិបត្តិការនៅកម្ពុជា ដែលត្រូវបានចាត់ទុកជាក្បាលម៉ាស៊ីនជំរុញកំណើន ។

ជាកិច្ចបញ្ចប់ និងជាថ្មីម្តងទៀត, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណដល់ ADB សម្រាប់ការរួមចំណែកក្នុងការគាំទ្រដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលនេះជារបៀបវារៈមួយនៃ **"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១"** សំដៅពង្រឹងភាពប្រកួតប្រជែង និងជំរុញល្បឿននៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន និងបានគូសរំលេចអំពីគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូល ព្រមទាំងស្នើឱ្យ ADB បន្តការគាំទ្រលើកិច្ចអភិវឌ្ឍន៍កម្ពុជាឱ្យសម្រេចបាននូវ **"ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០"** តាមរយៈការផ្តល់ហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានខ្ពស់ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានជូនពរឯកឧត្តម **ម៉ាសាស៊ូហ្គុ អាសាកាវ៉ា** ព្រមទាំងសហការីឱ្យទទួលបានជោគជ័យក្នុងដំណើរទស្សនកិច្ចរបស់ខ្លួននៅកម្ពុជា។